ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ០២/០៨—ខេមបូឌា អ៊ីបភែរ៉េល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **ស៊ីន គឹមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

ក- ភាគីនិយោជក

**ឈ្មោះ : ក្រុមហ៊ុន ខេមបូឌា អ៊ីបភែរ៉េល អ៊ិនជីសទ្រី (ក្រុមហ៊ុន ខេមបូឌា អ៊ីភែរ៉េល)**

អាសយដ្ឋាន : ផ្លូវជាតិលេខ ៤.ភូមិចំបក់. ឃុំវល្លិស. ស្រុកសំរោងទង. ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ : ០១៦ ៨៦៦ ០៨៩ ទូរសារលេខ : គ្មាន

**តំណាងភាគីនិយោជក :**

១-លោកស្រី អ៊ុន ហ៊ាង រដ្ឋបាលក្រុមហ៊ុន

២-លោក ម៉ុម ធន ជំនួយការរដ្ឋបាល

ខ- ភាគីកម្មករនិយោជិត

**ឈ្មោះ : សហព័ន្ធ សហជីពយុវជនខ្មែរ**

អាសយដ្ឋាន : ផ្លូវជាតិលេខ ៤.ភូមិចំបក់. ឃុំវល្លិស. ស្រុកសំរោងទង. ខេត្តកំពង់ស្ពឺ



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

ទូរស័ព្ទ : ០៩២ ៩០២ ៩៦៩

| | |
|---|---|
| ១-លោក នៅ ទិត្យា | មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ |
| ២-លោក ហ៊ុយ សុផារិទ្ធ | មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ |
| ៣-លោក អ៊ុន ដារ៉ា | មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ |
| ៤-អ្នកស្រី អ៊ុន ម៉ានី | ប្រធានសហជីពយុវជនខ្មែរ ក្រុមហ៊ុនខេមបូឌា អ៊ីបភែរ៉ែល |
| ៥-អ្នកស្រី ហួន ផានី | អនុប្រធានសហជីពយុវជនខ្មែរ ក្រុមហ៊ុនខេមបូឌា អ៊ីបភែរ៉ែល |
| ៦-អ្នកស្រី កៅ ធា | លេខាសហជីពយុវជនខ្មែរ ក្រុមហ៊ុនខេមបូឌា អ៊ីបភែរ៉ែល |

## **បញ្ហាក្នុងវិវាទ**

(នៅក្នុងរបាយការណ៍មិនសះជា)

ចំណុចទី២: សូមឱ្យក្រុមហ៊ុនចាត់វិធានការចំពោះប្រធានរដ្ឋបាលឈ្មោះ អ៊ុន ប៉ាង និងជំនួយការឈ្មោះ មាស សុភាព ដែលបានយកលុយពីកម្មករ-កម្មការិនីក្នុងម្នាក់ ៣០ ដុល្លារ ពេលចូលបំរើការងារនៅក្នុងក្រុមហ៊ុននេះ ។

ចំណុចទី៥: សូមឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលដល់កម្មករនៅរាល់ថ្ងៃទី៥ រៀងរាល់ខែ និងឱ្យចប់សព្វគ្រប់នៅម៉ោង ៤ល្ងាច ។

ចំណុចទី៨: រាល់ពេលក្រុមហ៊ុនធ្វើកិច្ចសន្យាការងារជាមួយកម្មករ សូមឱ្យក្រុមហ៊ុនចែកជូនដល់កម្មករនូវលិខិតកិច្ចសន្យាម្នាក់១ច្បាប់ ។ និងសូមឱ្យក្រុមហ៊ុនកាត់ប្រាក់ ៥ភាគរយ ឱ្យកម្មករកម្មការិនីនៅពេលបញ្ចប់កិច្ចសន្យា ៦ខែម្តង ។

ចំណុចទី៩: ពេលដែលកម្មការិនីយកក្មេងមកដាក់ សូមឱ្យក្រុមហ៊ុនរៀបចំអ្នកថែទាំក្មេងផង ។

ចំណុចទី១១: នៅពេលកម្មករចូលធ្វើការងារ ហើយក្រុមហ៊ុនធ្វើកាតជូនកម្មករ សូមកុំឱ្យក្រុមហ៊ុនយកលុយពីកម្មករ ក្នុងម្នាក់១០ ដុល្លារ ហើយត្រូវប្រគល់ឱ្យទៅកម្មករវិញចំពោះអ្នកដែលក្រុមហ៊ុនបានយករួចហើយ ។

## **អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី១០ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៥៩៦ ក.ប.វ/ក.ស្ក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០៨។

## នីតិវិធីមុនសវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងកិច្ចប្រជុំមុនសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ "A" វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**កាលបរិច្ឆេទនៃកិច្ចប្រជុំមុនសវនាការ :** ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ (វេលាម៉ោង ១៥:៣០ នាទី ដល់ម៉ោង ១៦:៣០ នាទី)។

**បញ្ហានៃនីតិវិធី :**

ក្រុមហ៊ុន ខេមបូឌា អ៊ីបកែរ៉េល មានអាសយដ្ឋានស្ថិតនៅផ្លូវជាតិលេខ ៤.ភូមិចំបក់. ឃុំវល្លិស. ស្រុកសំរោងទង. ខេត្តកំពង់ស្ពឺមានជួលកម្មករនិយោជិតចំនួន ៦៧៥ នាក់។

នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧ មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺបានទទួលលិខិតមួយស្តីពីសំណើរសុំជួយដោះស្រាយនូវការទាមទាររបស់សហជីពនិងកម្មករ-កម្មការិនីចំនួន១១ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះហើយ មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺបានអញ្ជើញភាគីក្រុមហ៊ុន សហជីព និងកម្មករនិយោជិតមកដោះស្រាយនៅ មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៧ និងផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ដោយបានទទួលលទ្ធផលសះជាចំនួន៥ចំណុច (ចំណុចទី១ ចំណុចទី៣ ចំណុចទី៤ ចំណុចទី៦ និងចំណុចទី១០)។ ចំណែកឯចំណុចទី៧ ភាគីទាំងពីរបានឯកភាពមិនដោះស្រាយទេ ដោយសារក្រុមហ៊ុនចាត់វិធានការចំពោះជនជាតិចិនឈ្មោះ ឡៅ គ័ង ដែលបានវាយកម្មការិនីមួយដបទឹកសុទ្ធ ព្រោះនៅពេលនេះគេបានលាឈប់ពីការងាររួចទៅហើយ។ ហេតុនេះហើយ ផ្អែកលើរបាយការណ៍មិនសះជារបស់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ចំណុចវិវាទដែលនៅសល់មានចំនួន៥ចំណុច (ចំណុចទី២ ចំណុចទី៥ ចំណុចទី៨ ចំណុចទី៩ និងចំណុចទី១១)។ ចំណុចមិនសះជាចំនួន ៥ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែមករា ឆ្នាំ ២០០៨។

នៅថ្ងៃទី០២ ខែមករា ឆ្នាំ ២០០៨ លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏ទទួលបានទទួលព័ត៌មានពីមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ និងពីភាគីនិយោជកថា ភាគីកម្មករកំពុងធ្វើកូដកម្ម ហើយស្នើរសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញបញ្ជាបញ្ឈប់កូដកម្មរបស់កម្មករនិយោជិត។ នៅថ្ងៃទី០២ ខែមករា

ឆ្នាំ២០០៨ ដដែល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកជ្រើសរើសអាជ្ញាកណ្តាលក្នុងបញ្ជីរៀង៧ខ្លួន ដើម្បីបង្កើតជាក្រុមអាជ្ញាកណ្តាលដោះស្រាយបញ្ហាវិវាទនៅក្នុងសំណុំរឿងនេះ។ ភាគីនិយោជកបានមកជ្រើសរើសអាជ្ញាកណ្តាលដោយផ្ទាល់ ចំណែកឯភាគីកម្មករនិយោជិតបានធ្វើការជ្រើសរើសអាជ្ញាកណ្តាលតាមទូរស័ព្ទ។ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលបានបង្កើតឡើងហើយ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៨ ក្រុមអាជ្ញាកណ្តាលបានចេញបញ្ជាឱ្យភាគីកម្មករនិយោជិតបញ្ឈប់ធ្វើកូដកម្ម ហើយតម្រូវឱ្យកម្មករនិយោជិតចូលធ្វើការវិញនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៨ ដើម្បីរង់ចាំក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោះស្រាយលើអង្គសេចក្តីនៃវិវាទការងារនេះ។ ប៉ុន្តែរហូតមកដល់ថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងតាមរយៈលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតមិនបានត្រឡប់ចូលទៅធ្វើការតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ តែនៅបន្តធ្វើកូដកម្មដដែល ព្រោះនិយោជកមិនបានអនុញ្ញាតិឱ្យថ្នាក់ដឹកនាំសហជីពបីនាក់ ដែលក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារចូលធ្វើវិញ។

បន្ទាប់ពីទទួលដំណឹងពីការបន្តធ្វើកូដកម្មរបស់កម្មករនិយោជិតមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានស្នើឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលអញ្ជើញភាគីកម្មករនិយោជិតនិងភាគីនិយោជក មកជួបប្រជុំមុនសវនាការ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨។ ភាគីនិយោជក និង ភាគីកម្មករនិយោជិតមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅក្នុងការជួបប្រជុំមុនសវនាការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសាកសួរភាគីអំពីបញ្ហាការឈប់ធ្វើកូដកម្មរបស់ភាគីកម្មករនិយោជិត និងការអនុញ្ញាតិរបស់ភាគីនិយោជកឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនរៀង៧ខ្លួន។ ភាគីកម្មករនិយោជិតបានលើកឡើងថាពួកគេមិនចូលធ្វើការទេ ប្រសិនបើថ្នាក់ដឹកនាំសហជីពបីនាក់មិនត្រូវបាន ក្រុមហ៊ុនអនុញ្ញាតិឱ្យចូលធ្វើការនោះ។ ចំណែកឯភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនបានបើកទ្វារឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការ ប៉ុន្តែ កម្មករនិយោជិតមិនព្រមចូលធ្វើការទេ។ ចំណែកឯថ្នាក់ដឹកនាំសហជីពបីរូបនោះ ក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងាររបស់ពួកគេហើយ។ ក្រោយពីស្តាប់ភាគីទាំងខាងរួចហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានស្នើរឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនរៀង៧ខ្លួន ហើយស្នើរឱ្យនិយោជកអនុញ្ញាតិឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនរៀង៧ខ្លួនដែរ ដើម្បីទុកលទ្ធភាពឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តនីតិវិធីដោះស្រាយវិវាទទាំងនេះតាមច្បាប់ស្តីពីការងារ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទុកពេលឱ្យភាគីទាំងពីរពិចារណាលើសំណើរនេះ រហូតដល់ថ្ងៃច័ន្ទ ទី១៤ ខែមករា ឆ្នាំ២០០៨ ប្រសិនបើភាគីទាំងពីរមានចេតនាពិតប្រាកដឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយចំណុចវិវាទដែលមិនសះជានេះ។ ក្នុងករណីដែលភាគីទាំងពីរមិនគោរពតាមការស្នើរសុំនេះទេ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាលលើសំណុំរឿងនេះទេ។

ប៉ុន្តែ រហូតមកដល់ថ្ងៃច័ន្ទទី១៤ ខែមករា ឆ្នាំ២០០៨ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងពីភាគីទាំងពីរថា កម្មករនិយោជិតមិនត្រឡប់ចូលធ្វើការទេ ហើយភាគីក្រុមហ៊ុនបានបើកទ្វារឱ្យកម្មករ

និយោជិតទាំងអស់ចូលធ្វើការវិញទាំងអស់ លើកលែងតែថ្នាក់ដឹកនាំសហជីពបីនាក់។ ប៉ុន្តែកម្មករនិយោជិតទាំងអស់មិនព្រមចូលធ្វើការទេ ដោយសារតែនិយោជកមិនអនុញ្ញាតិឱ្យថ្នាក់ដឹកនាំសហជីពទាំងបីនាក់ចូលធ្វើការ។

ហេតុនេះហើយនៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោម:

**តស្លុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី :** គ្មាន

**ឯកសារ ទស្លុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១-លិខិតស្តីពីការជូនដំណឹងការផុតរលត់នៃកិច្ចសន្យាការងារ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ របស់ឈ្មោះ ហួន ផានី. កៅ ធា. អ៊ុន ម៉ានី។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :** គ្មាន

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូឌា អ៊ីបភែរ៉េល លេខ ៥៩៦ ក.ប.វ/ក.ស្ក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧

២-កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខេមបូឌា អ៊ីបភែរ៉េល ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១-លិខិតអញ្ជើញភាគីកម្មកករនិយោជិត នៃក្រុមហ៊ុនកាត់ដេរ ខេមបូឌា អ៊ីបភែរ៉េល ចូលរួមផ្តល់ពត៌មាន លេខ ០១០ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨

២- លិខិតអញ្ជើញនាយកក្រុមហ៊ុនកាត់ដេរ ខេមបូឌា អ៊ីបភែរ៉េល ចូលរួមផ្តល់ពត៌មាន លេខ ០១១ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨

៣-សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០១ កបអ. ចុះថ្ងៃទ០៣ ខែមករា ឆ្នាំ២០០៨

**ការរកឃើញអង្គហេតុ:**

THE ARBITRATION COUNCIL

មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន។

## **ហេតុផលនៃសេចក្តីសម្រេច**

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា:

*"ក្នុងកំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"*

បន្ថែមលើនេះទៀត នៅក្នុងសេចក្តីបញ្ជាមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករកំពុងធ្វើកូដកម្ម ឬនិយោជកធ្វើការឡុកអៅ ។

ទាក់ទងនឹងការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្នុងពេលដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះបានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗដូចខាងក្រោម:

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តី ជូនដំណឹងនេះចែងថា *"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើ វិវាទការងាររួម ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីព កម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម ។"*

នៅក្នុងសំណុំរឿង ៧៧/០៥-ហ្វ្រង់កូ នីតធីង ហ្គាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា *នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។*

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម និងសំណុំរឿងលេខ ៣៤/០៦-ហ្គោល ហ្វេម ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងទាំងនោះចោល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្ត

ធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ (សូមមើលបន្ថែមក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ៩៧/០៧-ស៊ូត វ៉ៃ ។)

ទាក់ទងនឹងការការធ្វើឡុកអៅរបស់និយោជកនៅក្នុងពេលដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ បានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដូចខាងក្រោមៈ

នៅក្នុងសំណុំរឿងលេខ២២/០៧-ផាកវីយូ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងនេះ ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មហើយ និយោជកនៅតែឡុកអៅ ក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សា អាជ្ញាកណ្តាល ។

ផ្អែកលើការបកស្រាយខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាភាគីទាំងពីរ ពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយថាពួកគេមានបំណងយកវិវាទការងារនេះ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ព្រោះភាគីទាំងពីរបានប្រកាន់យកគោលជំហររៀងៗខ្លួនហើយមិនគោរពតាមបញ្ជា និង ការស្នើសុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ហេតុដូច្នេះ ដើម្បីឱ្យស្របគ្នាទៅនឹងច្បាប់ ព្រមទាំងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា មិនបន្តដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះទេ ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ :

## សម្រេច

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០២/០៨-ខេមបូឌា អាភែរ៉ែល នេះទេ ។

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ឹង សុន្ធី**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ស៊ីន គឹមសាន**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------------

THE ARBITRATION COUNCIL